## ត្រឡប់ទៅធ្វើការវិញរហ័ស

អ្នកត្រូវតែធ្វើការទាក់ទងទៅនិយោជកយ៉ាងហោចណាស់ឲ្យបានបីកន្លែង ឬចូលរួមក្នុងសកម្មភាពស្វែងរកការងារបីដងតាមការិយាល័យ Worksource ក្នុងស្រុករបស់អ្នក ក្នុងអាទិត្យនិមួយៗ ដែលអ្នកដាក់ពាក្យទាមទារកម្រៃ ។ អញ្ជើញមកការិយាល័យ Worksource ដើម្បីចង់ដឹងអំពីធនធានទាំងឡាយដែលមានដោយឥតគិតថ្លៃ ដែលអ្នកត្រូវការសំរាប់រកការងារធ្វើ ។ ធនធានទាំងនោះមានរួមទាំង រោងជាង កុំព្យូទ័រ ម៉ាស៊ីនថតចំឡង ទូរស័ព្ទ ទូរសារ ចូលប្រើអ៊ីនធើណិត និងសារព័ត៌មាន ។ ចូលបណ្តាញអ៊ីនធើណិត www.go2worksource.com ឬទូរស័ព្ទមកយើងដើម្បីសួរគេអំពីការិយាល័យដែលនៅជិតអ្នក ។

### ការិយាល័យ WorkSource

| | |
|---|---|
| Aberdeen • 360.533.9318 | Omak • 509.826.7310 |
| Auburn • 253.804.1177 | |
| Bellingham • 360.676.1521 | Port Angeles • 360.457.2100 |
| Bremerton • 360.337.4810 | Port Hadlock • 360.379.5036 |
| Chehalis • 360.748.2360 | Pullman • 509.332.6549 |
| Colville • 509.685.6158 | Redmond • 425.861.3700 |
| Ellensburg • 509.925.5311 | Renton • 206.205.3500 |
| Everett • 425.258.6300 | Seattle (North) • 206.440.2500 |
| | Seattle (Rainier) • 206.721.6000 |
| Goldendale • 509.773.5503 | Shelton • 360.427.2174 |
| Kelso • 360.577.2250 | South Bend • 360.875.9470 |
| Kennewick • 509.734.5900 | Spokane • 509.532.3000 |
| Lakewood • 253.589.7119 | Stevenson • 509.427.4464 |
| Long Beach • 360.642.6213 | Sunnyside • 509.836.5405 |
| | Tacoma • 253.593.7300 |
| | Vancouver • 360.735.5000 |
| Moses Lake • 509.766.2559 | Walla Walla • 509.527.4393 |
| Mount Vernon • 360.416.3500 | Wenatchee • 509.665.6605 |
| Oak Harbor • 360.675.5966 | White Salmon • 509.493.1210 |
| Olympia • 360.704.3600 | Yakima • 509.574.0105 |

ក្រសួងសន្តិសុខការងារគឺជានិយោជកបើកឲ្យមានឱកាសស្មើគ្នា និងជាអ្នកផ្តល់ការបំរើសំរាប់កម្មវិធី និងសេវាកម្មជាច្រើន ។ គ្រឿងជំនួយឯទៀតៗ និងសេវាជាច្រើនអាចមានជូនទៅតាមការស្នើសុំសំរាប់ជនដែលមានពិការភាព ។ គ្រឿងជំនួយទាំងនោះមានរួមនូវ អ្នកបកប្រែភាសាមានគុណសម្បត្តិ និងឧបករណ៍ទូរស័ព្ទ (TTY) សំរាប់មនុស្សដែលមានបញ្ហាស្តាប់ឬនិយាយ ។ បុគ្គលទាំងឡាយដែលមានកំរិតយល់ដឹងផ្នែកភាសាអង់គ្លេសអាចស្នើសុំសេវាបកប្រែភាសាដោយឥតគិតថ្លៃសំរាប់ភ្ញៀវដើម្បីដឹកនាំធ្វើការជាមួយ ក្រសួង ។

EMS 10304 . Rev 6/08 . UI-jsk-apply-CA

# នៅតាមបណ្តាញអ៊ិនធើណិត
# នៅតាមទូរស័ព្ទ

# ដាក់ពាក្យសុំសំរាប់កម្រៃ សំណងពេលឥតការងារធ្វើ

Employment Security Department
WASHINGTON STATE

## ដាក់ពាក្យសុំតាមបណ្ដាញអ៊ិនធើណិត

esd.wa.gov

## តើខ្ញុំត្រូវដាក់ពាក្យសុំសំរាប់កម្រៃសំណងពេលឥតការងារធ្វើរបៀបណា?

ចូលក្នុងបណ្ដាញអ៊ិនធើណិត esd.wa.gov ដើម្បីដាក់ពាក្យសុំសំរាប់កម្រៃសំណងពេលឥតការងារធ្វើ ។ អ្នកអាចដាក់ពាក្យសុំតាមបណ្ដាញអ៊ិនធើណិតលុះត្រាតែ:

- អ្នកបានធ្វើការនៅក្នុងរដ្ឋពីរ ឬលើសក្នុងរយៈពេល 24 ខែកន្លងមក
- អ្នកបានធ្វើការនៅក្នុងរដ្ឋតែមួយ ក្រៅពីរដ្ឋវ៉ាស៊ីនតោនក្នុងរយៈពេល 24 ខែកន្លងមក
- អ្នកមានពិការទាំងស្រុងសំរាប់រយៈពេលយ៉ាងហោចណាស់ 13 អាទិត្យជាប់ៗគ្នា ដោយមកពីគ្រោះថ្នាក់ទាក់ទងនឹងការងារ ឬគ្រោះថ្នាក់ដែលមិនទាក់ទងនឹងការងារ ឬជំងឺ ហើយអ្នកត្រូវបានបញ្ចេញដោយ វេជ្ជបណ្ឌិតក្នុងរយៈពេល 12ខែ ។

## តើខ្ញុំត្រូវការអ្វីខ្លះ ពេលណាខ្ញុំដាក់ពាក្យសុំ?

ដើម្បីដាក់ពាក្យសុំសំរាប់កម្រៃសំណងពេលឥតការងារធ្វើ អ្នកនឹងត្រូវការ:

- អត្តលេខសន្តិសុខសង្គម
- ឈ្មោះ និងអសយដ្ឋាននិយោជកគ្រប់ៗរូបដែលអ្នកធ្វើការឲ្យ ក្នុងរយៈពេលពីរឆ្នាំកន្លងមក
- ដាក់កាលបរិច្ឆេទពេលអ្នកចាប់ផ្ដើម និងឈប់ធ្វើការសំរាប់និយោជកនិមួយៗ
- មូលហេតុដែលអ្នកឈប់ធ្វើការនៅតាមកន្លែងនិមួយៗ
- លេខចុះឈ្មោះជាអណិកជនរបស់អ្នក បើអ្នកមិនមែនជាពលរដ្ឋអាមេរិកាំង

បើសិនជាអ្នកនៅក្នុងជួរកងទ័ពក្នុងរវាង 24ខែកន្លងមក យើងក៏នឹងសុំឲ្យអ្នកផ្ញើទូរសារ ឬផ្ញើតាមប្រៃសណីយ៍នូវក្រដាសចំឡងអំពីការរំសាយចេញពីជួរកងទ័ព (ក្រដាសលេខ DD214) ។

## តើខ្ញុំត្រូវដាក់ពាក្យសុំនៅកន្លែងណា?

បើអ្នកមានកុំព្យូទ័រ អ្នកអាចដាក់ពាក្យសុំពីផ្ទះរបស់អ្នកបាន ។ បើគ្មានទេ អ្នកអាចប្រើកុំព្យូទ័រនៅតាម បណ្ណាល័យតាមស្រុករបស់អ្នក ឬតាមការិយាល័យ WorkSource ។

## តើធ្វើយ៉ាងណាបើខ្ញុំគ្មានកុំព្យូទ័រ?

អ្នកក៏អាចដាក់ពាក្យសុំសំរាប់កម្រៃសំណងពេលឥតការងារធ្វើតាមទូរស័ព្ទបានដែរ ។ សូមទូរស័ព្ទមកលេខ 1-800-318-6022 (TTY 1-800-365-8969) ។

## តើខ្ញុំត្រូវទូរស័ព្ទមកពេលណា?

យើងមាននិកាសជួយអ្នកចាប់ពីថ្ងៃច័ន្ទ រហូតដល់ថ្ងៃសុក្រ ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច លើកលែងតែថ្ងៃបុណ្យរដ្ឋ ។ យើងប្រហែលជាពន្យាម៉ោងធ្វើការក្នុងរយៈពេលមមារញឹកខ្លាំង ។

បើសិនជាតួលេខក្នុងអត្តលេខសន្តិសុខសង្គមរបស់អ្នកចប់ត្រង់លេខ:

0 ដល់លេខ 3, ទូរស័ព្ទមកថ្ងៃច័ន្ទ

4 ដល់លេខ 7, ទូរស័ព្ទមកថ្ងៃអង្គារ

8 ដល់លេខ 9, ទូរស័ព្ទមកថ្ងៃពុធ

សូមទូរស័ព្ទមកនៅថ្ងៃកំណត់ត្រូវនឹងលេខរបស់អ្នក ។ បើសិនជាអ្នកខកខានថ្ងៃរបស់អ្នក អ្នកអាចទូរស័ព្ទមក នៅថ្ងៃពុធ ថ្ងៃព្រហស្បតិ៍ ឬថ្ងៃសុក្រនៅក្នុងអាទិត្យជាមួយគ្នាដោយគ្មានការយឺតយ៉ាវក្នុងការបង់ប្រាក់ឡើយ ។

អតិថិជនដែលមានការទាមទារកម្រៃនេះនៅសកម្មនៅឡើយ អាចទូរស័ព្ទមកថ្ងៃណាក៏បានដែរក្នុងអាទិត្យ ។

## តើធ្វើយ៉ាងណាបើខ្ញុំត្រូវការអ្នកបកប្រែ?

ទូរស័ព្ទមក មជ្ឈមណ្ឌលទូរស័ព្ទតាមលេខ 1-800-318-6022 ។ មានអ្នកបកប្រែភាសាសំរាប់ជួយអ្នក ដោយឥតយកថ្លៃឈ្នួលឡើយ ។

## តើធ្វើយ៉ាងណាបើខ្ញុំមានពិការភាព?

បើពិការភាពរបស់អ្នករារាំងអ្នកមិនឲ្យប្រើកុំព្យូទ័រ ឬទូរស័ព្ទ សូមអញ្ជើញមកការិយាល័យ WorkSource តាមស្រុករបស់អ្នក ។ យើងនឹងជួយអ្នកដាក់ពាក្យសំរាប់កម្រៃសំណងពេលឥតការងារធ្វើ ។